**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ វីនតាយសកខ៍ ម៉េនូហ្វេកឈ័រ អិលធីឌី**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ វីនតាយសកខ៍ ម៉េនូហ្វេកឈ័រ អិលធីឌី**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២៣ វេលាម៉ោង ១០ព្រឹក នៅក្នុងរោងចក្រ **វីនតាយសកខ៍ ម៉េនូហ្វេកឈ័រ អិលធីឌី** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងមិនមានការបញ្ជាទិញគ្រប់គ្រាន់សម្រាប់ផលិត ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតសរុបចំនួន **៥៣២** នាក់ ស្រី **៤១៥**នាក់ ក្នុងចំណោមកម្មករសរុប៥៣២នាក់ ស្រី៤១៥ នាក់ រយៈពេលចំនួន២ខែ គឺចាប់ពីថ្ងៃទី២៣ ខែ មករា **ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៣ ខែ មិនា ឆ្នាំ ២០២៣** នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ ប្រាក់ឈ្នួលចំនួន **៣០**ដុល្លា ក្នុង១ខែ សម្រាប់កម្មករ និយោជិតម្នាក់ៗ ហើយបើកអោយកម្មករនិយោជិតនៅថ្ងៃទី **១០** នៃខែបន្ទាប់។

អង្គប្រជុំបានចប់វេលាម៉ោង១១ និង ០០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្អិតស្អាត និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

តាកែវ.ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២៣

**តំណាងកម្មករ និង តំណាងសហជីព** | ត.ប **នាយកក្រុមហ៊ុន**

WINTAI SOCK MANUFACTURE LTD.